# ការយល់ឃើញរបស់ខ្ញុំ

ដោយ ឡេារ មុយងិច
និសិត្សវិទ្យាស្ថានភាសាបរទេសនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

វគ្គទី៤ៈ ផ្តោតសំខាន់ទៅលើអំពើប្រល័យពូជសាសន៍ និងការអត់ឃ្លាន មានពន្យល់ពីធាតុផ្សំទាំងបី ដែលបង្ហាញថាជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ ការអង់ឃ្លានក្នុងរបបខ្មែរក្រហមមិនបានចាត់ទុកជាអំពើប្រល័យពូជសាសន៍នោះទេ បើយើងទៅតាមផ្លូវច្បាប់។

វគ្គទី៥ៈ ផ្តោតសំខាន់ទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ វាជាការវាយប្រហារទូទៅ រឺជាប្រព័ន្ធទៅលើប្រជាជនស៊ីវិល។ ក្នុងនោះរួមមានការសំលាប់រង្គាល ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌។

វគ្គទី៦ៈ ផ្តោតសំខាន់ទៅលើឧក្រិដ្ឋកម្មសង្គ្រាម ជាការប្រើប្រាស់នូវការបង្អត់អាហារប្រជាជន ជាមធ្យោបាយក្នុងការធ្វើសង្គ្រាម ការអត់ឃ្លានគឺបង្កឡើងដោយគោលនយោបាលរបស់រដ្ឋាភិបាលខ្មែរក្រហម ដែលជារដ្ឋាភិបាលផ្លូវការរបស់កម្ពុជា មិនមានការជាប់ពាក់ព័ន្ធ ទៅនឹងជំលោះប្រដាប់អាវុធជាមួយប្រទេសវៀតណាមឡើយ។

វគ្គទី៧ៈ ការអត់ឃ្លានក្នុងប្រទេសដទៃទៀត និងការផ្លាស់ប្តូរនៃការអត់ឃ្លាននាពេលបច្ចុប្បន្ន។

ចំពោះវគ្គទាំង៤ (៤ ៥ ៦ ៧) ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំឡើងពិតជាបានផ្តល់នូវចំណេះដឹងថ្មី និងសំខាន់ដល់រូបខ្ញុំផ្ទាល់ ថ្វីបើខ្ញុំជានិស្សិតច្បាប់ ខ្ញុំមិនដែលបានសិក្សា និងធ្វើការវិភាគទៅលើពាក្យទាំងបី និងលក្ខណៈខុសគ្នារបស់វា ដូចជា អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្ម

ប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។ យោងតាមវគ្គទាំង៤ ការប្រើពាក្យប្រល័យពូជសាសន៍មិនសូវជាត្រូវនោះទេ ហើយពាក្យឧក្រិដ្ឋកម្មសង្គ្រាម រឺឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ សមនឹងអ្វីដែលកើតឡើងក្នុងរបបខ្មែរក្រហម។ ចំណែកឯការអត់ឃ្លានវិញ មិនត្រឹមតែកើតឡើងក្នុងប្រទេសកម្ពុជាក្នុងទ្រង់ទ្រាយធំទេ នៅប្រទេសកូរ៉េខាងជើង និងតំបន់ដាហ្វ៊រ ក៏មានការអត់ឃ្លានធ្ងន់ធ្ងរដែរ។

ខ្ញុំយល់ឃើញថាកម្មវិធីនេះពិតជាល្អសម្រាប់ប្រជាជនខ្មែរ ដើម្បីអោយពលរដ្ឋទាំងអស់ ជាពិសេសយុវជន និងយុវនារីយល់ដឹងច្បាស់នូវអ្វីទៅជារបបខ្មែរក្រហម និងវត្តមានរបបនេះក្នុងប្រទេសកម្ពុជា។ កម្មវិធីនេះក៏បានជួយជាភស្តុតាងប្រវត្តិសាស្ត្រដែលហាមប្រាមនូវការកើតឡើងម្តងទៀតនូវអំពើឃោរឃៅនេះ។

My Reflection[1]
By Lor Muoyngich
From the Institute of Foreign Languages at the Royal University of Phnom Penh

Part 4 focused on genocide and starvation, delineating the three main components which contribute to the crime of genocide. From a legal standpoint, the starvation which occurred during the Khmer Rouge regime is not considered genocide.

Part 5 focused on crimes against humanity, which refer to any actions committed as part of a widespread and systematic attack directed against any civilian population, including extermination, persecution, and inhumane acts.

Part 6 focused on war crimes and the use of starvation as a means of war. Widespread starvation resulted from policies of the Khmer Rouge, which was the official government of Cambodia at the time. It had nothing to do with the border clash with the Vietnamese.

Part 7 addressed starvation in other countries and starvation in contemporary society.

All of the parts 4 through 7 of this radio program, which was organized by the Documentation Center of Cambodia, are important and provided me with new knowledge. Though I am a law student, I have never encountered the words 'genocide, crimes against humanity, or war crimes,' or known the specific meanings of those terms.

Based on the information presented in Part 4, I feel the use of the term 'genocide' to describe the Khmer Rouge regime is not appropriate. The charges of war crimes and crimes against humanity are more accurate within the context of the Khmer Rouge regime. Moreover, widespread starvation was experienced not only in Cambodia, but also in North Korea, Darfur and other regions.

In my opinion, this program is very beneficial for Khmer people. In particular, it allows Cambodian youth to learn more about Khmer Rouge history and provides historical evidence which can help prevent such a regime from happening ever again.

[1] Translated by Hing Tetmony; edited by Elaine McKinnon